# I . ទីស្តីការគណៈរដ្ឋមន្ត្រី

## ១-អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៩៥

### អនុក្រឹត្យលេខ ៤៦ អនក្រ.បក

អំពីការបញ្ជាចំណាយឥតគ្រោងទុក ដែលមានលក្ខណៈ
ចាំបាច់ និង បន្ទាន់ របស់ក្រសួងការពារជាតិ

* * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងអនុក្រឹត្យលេខ ៤១ អនក្របក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៥ ស្តីពីការបញ្ជាចំណាយឥតគ្រោងទុក ដែលមានលក្ខណៈចាំបាច់ និងបន្ទាន់របស់ក្រសួង ការពារជាតិ
- យោងតាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

**មាត្រា ១ :** កំណត់អោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោះស្រាយថវិកាសំរាប់ការចំណាយ ដែលចាត់ទុកជាតម្រូវការប្រញាប់របស់រាជរដ្ឋាភិបាល ដូចខាងក្រោម :

www.pheakdeylaw.com

១-ការចំណាយសំរាប់សាងសង់បន្ទាយសុវត្ថិភាព អោយកំលាំងការពារនាយករដ្ឋមន្ត្រីទី ១ មានទឹកប្រាក់ចំនួន ៤៨៧.០០០ ដុល្លារអាមេរិក ស្មើនឹង ១.១២០.១០០.០០០៖០០ (មួយពាន់មួយរយម្ភៃលានមួយរយពាន់រៀលគត់ គិតតាមអត្រាថ្ងៃទី ៣១-៥-៩៥ ២.៣០០៖០០ ក្នុងមួយដុល្លារអាមេរិក ។

២-ការចំណាយមានចំនួនទឹកប្រាក់ ៤២៤.៦៣៣,៥០ ដុល្លារអាមេរិក (បួនរយម្ភៃបួនពាន់ប្រាំមួយរយសាមសិបបីដុល្លារអាមេរិក និង ហាសិបសេន) សំរាប់ទូទាត់ថ្លៃទិញយន្តហោះ Y-12 ចំនួន ២ គ្រឿង ។

**មាត្រា ២ :** ការកំណត់ក្នុងការដោះស្រាយថវិកា ដែលបានចែងក្នុងចំណុចទី ៥ មាត្រា ១ នៃអនុក្រឹត្យលេខ ៤១ អនក្របក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៥ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អាជ្ញាធរពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះអោយបានសំរេច ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៦៨ អនក្រ.បក**

ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

www.pheakdeylaw.com